**នៅពេលដែលជ្រើសរើសធុងសម្រាប់ដាក់ទឹកហូប សូមប្រាកដថា៖**

- ✔ ធុងថ្មី ឬមិនដែលដាក់សារធាតុពុលពីមុន
- ✔ មានគម្រប
- ✔ មាត់ធុងធំល្មមអាចលូកដៃលាងសម្អាតធុងបាន
- ✔ មានក្បាលរ៉ូប៊ីណេ ឬអ្នកអាចចោះរន្ធលើធុងនោះដាក់ក្បាលរ៉ូប៊ីណេបាន

## ដាំ ឬចម្រោះ និងរក្សាទុកទឹកហូបឱ្យមានសុវត្ថិភាព

១ លាងសម្អាតធុងទឹកនឹងសាប៊ូ

២ ដាំ ឬចម្រោះ

៣ ទុកឱ្យត្រជាក់ ចាក់ចូលក្នុងធុង ហើយគ្របវា

៤ ផឹក

៥ នៅពេលទឹកជិតអស់ ធ្វើជំហានទី១-៣ឡើងវិញសម្រាប់ធុងទីពីរ

អ្នកនឹងទទួលបានការជួយចោះរន្ធសម្រាប់ដាក់ក្បាលរ៉ូប៊ីណេ និងស្ទិកគ័ររំលឹកសម្រាប់បិទលើឧបករណ៍ទឹកស្អាត និងអនាម័យរបស់អ្នកពេលដែលយើងចុះពិនិត្យដល់ផ្ទះបន្ទាប់ពីទទួលបានការជូនដំណឹងពីអ្នក។




ស្ទិកគ័រចំនួន ៥

អ្នកនឹងទទួលបានសាប៊ូដុំចំនួន ២ និងថង់ដាក់សាប៊ូចំនួន ២ ដោយឥតគិតថ្លៃផងដែរ ប្រសិនបើអ្នកបានត្រៀម ឬបានដំឡើងឧបករណ៍ទឹកស្អាត និងអនាម័យរួចរាល់បានត្រឹមត្រូវ។




**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងជនបង្គោល**

..............................................................................

..............................................................................

# មើលឃើញស្អាត មិនប្រាកដថាមានសុវត្ថិភាពទេ



**ការពារខ្លួនអ្នក និងគ្រួសាររបស់អ្នកពីមេរោគទាំងឡាយដោយការលាងសម្អាតដៃរបស់អ្នកនឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង ៥ និងហូបទឹកដែលបានដាំ ឬចម្រោះ និងរក្សាទុកឱ្យមានសុវត្ថិភាពតែប៉ុណ្ណោះ**

USAID ជំនួយពីប្រជាជនអាមេរិក

psi Cambodia

## ធ្វើកន្លែងលាងសម្អាតដៃដោយខ្លួនឯង

**អ្នកនឹងត្រូវការដូចជា**

ធុងទឹកមានគម្រប (ស្អាត) ២
កន្ទន់ត្រងទឹកកខ្វក់ ២
ជើងទម្រកន្លែងលាងសម្អាតដៃ ២
ក្បាលរ៉ូប៊ីណេ ២





១ ចោះរន្ធសម្រាប់ការដាក់ក្បាលរ៉ូប៊ីណេជិតបាតធុងទឹក

២ ដាក់ក្បាលរ៉ូប៊ីណេនៅចំណុចចោះលើធុងនោះហើយធានាថាដាក់ត្រូវទាំងសងខាងធុង

៣ ស្វានចោះរន្ធតូចមួយនៅគម្របធុងទឹក ដើម្បីឱ្យខ្យល់ចូល

៤ បិទស្ទិកគ័រលាងសម្អាតដៃ“មុនពល” នៅលើជ្រុងនៃធុងលាងសម្អាតដៃសម្រាប់ដាក់នៅផ្ទះបាយ និងស្ទិកគ័រ “ក្រោយពេល”បិទនៅលើធុងលាងសម្អាតដៃដាក់នៅបង្គន់

៥ ដាក់ជើងទម្រធុងលាងសម្អាតដៃមួយនៅក្បែរផ្ទះបាយ/កន្លែងហូបបាយ និងមួយទៀតនៅក្រៅបង្គន់ ឬបន្ទប់ទឹក

៦ ចាក់ទឹកចូលធុងហើយដាក់ធុងលើជើងទម្រ

៧ គ្របធុងទឹកលាងសម្អាតដៃ

៨ ដាក់កន្ទន់នៅពីក្រោមក្បាលរ៉ូប៊ីណេដើម្បីត្រងទឹកកខ្វក់

៩ ដាក់សាប៊ូដុំក្នុងថង់សំណាញ់ហើយព្យួរលើក្បាលរ៉ូប៊ីណេនីមួយៗ